

ផលប្រយោជន៍នៃការបម្រើសេវា



តើព្រះជាម្ចាស់បានប្រទានមធ្យោបាយមួយ ដើម្បីរំដោះ
យើងចេញពីអាណាចក្រងងឹត ឲ្យក្លាយជាអ្នកទទួលមរតក
ព្រះរាជ្យនៃពន្លឺឬទេ? បាទ/ចាស់ ព្រះអង្គបានប្រទាន មែន។
ព្រះអង្គបានប្រទានមធ្យោបាយមួយ
របស់ព្រះយេស៊ូគ្រិស្តជំនួសយើង។
យកបណ្តាសាយើងនៅលើឈើឆ្កាង ស្តាប់បង្គាប់របស់យើង
ដើម្បីឲ្យយើងអាចទទួលព្រះពរ តាម
រយៈការស្តាប់បង្គាប់របស់ព្រះយេស៊ូគ្រិស្ត។ ព្រះពរទាំងនេះ
មាននៅពាសពេញព្រះរាជ្យនៃពន្លឺ។ ទាំងបណ្តាសាទាំងព្រះ
ពរសុទ្ធតែមានឥទ្ធិពលលើផ្នែកសំខាន់ទាំងបី នៃជីវិតរបស់ យើងគឺ៖
ផ្នែកវិញ្ញាណ ផ្នែករូបកាយ និងផ្នែកសម្ភារៈ។

ផលប្រយោជន៍ខាងវិញ្ញាណ

តើព្រះគ្រិស្តបានរំដោះយើងឲ្យរួចពីបណ្តាសាខាវិញ្ញាណ អ្វីខ្លះ?
ដូចគ្នាដែរ តើព្រះយេស៊ូបានបម្រុងព្រះពរខាង
វិញ្ញាណអ្វីខ្លះទុកសម្រាប់យើង?

ជាបឋម សូមពិនិត្យមើល មូលហេតុ
ដែលនាំឲ្យយើងទទួលបានព្រះពរ និងមូលហេតុ
ដែលនាំឲ្យទទួលបណ្តាសា។

> «ប្រសិនបើអ្នកយកចិត្តទុកដាក់ស្តាប់តាមព្រះបន្ទូលរបស់
> ព្រះអម្ចាស់ ជាព្រះរបស់អ្នក ដោយកាន់
> និងប្រតិបត្តិតាមបទ បញ្ជាទាំងប៉ុន្មានរបស់ព្រះអង្គ
> ដូចខ្ញុំបង្គាប់នៅថ្ងៃនេះ ព្រះ អម្ចាស់
> ជាព្រះរបស់អ្នកនឹងប្រទានអោយអ្នកបានទៅជា
> ប្រជាជាតិមួយ ប្រសើរជាងប្រជាជាតិទាំងអស់នៅលើផែន
> ដី។ ប្រសិនបើអ្នកស្តាប់តាមព្រះបន្ទូលនៃព្រះអម្ចាស់ ជាព្រះ
> របស់អ្នក ព្រះអង្គនឹងប្រទានពរគ្រប់យ៉ាងដល់អ្នក»
> (ទុតិយកថា២៨:១-២)។

បន្ទាប់មក លោកម៉ូសេប្រាប់យើងអំពីមូលហេតុ

> ដែលនាំឲ្យយើងទទួលបណ្តាសា។
> ប្រសិនបើអ្នកមិនស្តាប់ព្រះសូរសៀង
> របស់ព្រះអម្ចាស់ជាព្រះនៃអ្នកប្រសិនបើអ្នកមិនកាន់
> ឬប្រតិបត្តិតាមបទបញ្ជា និង
> ច្បាប់ទាំងប៉ុន្មានដែលខ្ញុំប្រគល់អោយអ្នកនៅថ្ងៃនេះ
> នោះអ្នកនឹងទទួលបានបណ្តាសាដូចតទៅ”(ទុតិយកថា២៨:

១៥)។

វាជារឿងសំខាន់ណាស់
ក្នុងការស្វែងយល់អំពីភាពខុសគ្នាកើតចេញពីការសម្រេចចិត្ត
ដែលនាំឲ្យយើងទទួលព្រះពរ និងទទួលបណ្តាសា។
យើងអាចសង្ខេបភាពខុសគ្នាដោយពាក្យមួយឃ្លា
ប៉ុន្តែវាមានន័យសំខាន់ខ្លាំងណាស់៖“ស្តាប់ព្រះសូរសៀងរបស់ព្រះអម្ចាស់ ជាព្រះរបស់អ្នក ” ។

គោលដៅទាំងមូលនាំឲ្យយើងទទួលបាននូវសុខុមាលភាព ឬ
ក៏គ្រោះមហន្តរាយ
វាអាស្រ័យទៅលើសម្លេងយើងស្តាប់។ការស្តាប់ព្រះសូរសៀងរបស់ព្រះអម្ចាស់ ហើយប្រតិបត្តិតាមបង្គាប់ ដែលព្រះអង្គមានព្រះបន្ទូលនឹងនាំឲ្យយើងទទួលព្រះពរ។ ប៉ុន្តែ
ការមិនស្តាប់តាមព្រះសូរសៀងរបស់ព្រះអម្ចាស់
នឹងនាំឲ្យទទួលបណ្តាសាជាច្រើន។ ពិតណាស់
បើយើងគ្រាន់តែស្តាប់ព្រះសូរសៀងរបស់ព្រះអម្ចាស់ មិនគ្រប់គ្រាន់ទេ
ទាល់តែយើងប្រតិបត្តិតាមបង្គាប់របស់ព្រះអង្គផងដែរទើបបាន។
ទុយទៅវិញ យើងមិនអាចស្តាប់តាមបង្គាប់ព្រះជាម្ចាស់បានទេ
ទាល់តែយើងបានស្តាប់ឮព្រះសូរសៀងរបស់ព្រះអង្គជាមុនសិន
ពីព្រោះព្រះសូរសៀងរបស់ព្រះអង្គ តម្រូវឲ្យយើងធ្វើតាមទ្រង់។

គ្រោះថ្នាក់ខាងវិញ្ញាណដ៏ធំ ដែលគ្រិស្តបរិស័ទទូទៅ
ប្រឈមមុខនោះគឺ
គេលែងមានញ្ញាណស្តាប់ឮព្រះសូរសៀងរបស់ព្រះជាម្ចាស់ទៀត។
គ្រិស្តបរិស័ទជាច្រើនអាចបន្តធ្វើសកម្មភាពតាមបែបសាសនា
និងបំពេញកាតព្វកិច្ចរបស់ពួកគេតាមទម្លាប់
និងមានលក្ខណៈជាផ្លូវការ(របៀបរស់នៅទៅតាមប្បធម៌ដែលគេមាន)
ដោយពុំបានយល់ដឹងបន្ថែមទៀត
អំពីព្រះសូរសៀងរបស់ព្រះជាម្ចាស់។តាមរយៈការចែកចាយទាំងអស់នេះ មានតម្រូវការតែមួយគត់គឺថា
ព្រះជាម្ចាស់ចង់ឲ្យប្រជារាស្ត្ររបស់ព្រះអង្គស្តាប់តាមព្រះសូរសៀងរបស់ទ្រង់។

ព្រះគម្ពីរចែងថា:

ព្រះអម្ចាស់មានព្រះបន្ទូលអំពីតម្រូវការនេះ
ដោយផ្ទាល់នៅក្នុងអត្ថបទគម្ពីរ យេរេមា ៧:២២-២៣។
តាមរយៈអត្ថបទពីរខនេះ ព្រះជាម្ចាស់បានពន្យល់នូវអ្វី
ដែលព្រះអង្គចង់ឲ្យប្រជាជនអ៊ីស្រាអែលអនុវត្តតាម។

> «ដ្បិតនៅថ្ងៃដែលយើង
> បាននាំបុព្វបុរសរបស់អ្នករាល់គ្នាចេញពីស្រុកអេស៊ីប
> យើងពុំបាននិយាយអ្វីជាមួយពួកគេ
> ហើយយើងក៏ពុំបានបង្គាប់ពួកគេស្តីអំពីតង្វាយដុតនិងយញ្ញបូជាដែរ។ យើងគ្រាន់តែបង្គាប់ ពួកគេថា
> “ចូរស្តាប់សំឡេងយើង
> ដើម្បីអោយយើងធ្វើជាព្រះរបស់អ្នករាល់គ្នាហើយអ្នករាល់គ្នាធ្វើជាប្រជារាស្ត្ររបស់យើង...”។

សូមកត់សម្គាល់ពីតម្រូវការដ៏សាមញ្ញរបស់ព្រះអម្ចាស់ដើម្បីឲ្យព្រះអង្គ
ធ្វើជាព្រះជាម្ចាស់របស់យើងរាល់គ្នា
ហើយយើងរាល់គ្នាធ្វើជាប្រជារាស្ត្ររបស់ព្រះអង្គ។

ប្រហែលជាលោកអ្នកធ្លាប់គិតថា សញ្ញាថ្មីខុសពី សញ្ញាចាស់
ប៉ុន្តែវាមិនមែនជាពិតទេ។ គោលការណ៍ពិតជា ដូចគ្នាបេះបិត។
ព្រះយេស៊ូសង្ខេបវាមកតែមួយឃ្លាថា៖
“ចៀមរបស់ខ្ញុំតែងស្តាប់សំឡេងខ្ញុំ ខ្ញុំស្គាល់ចៀមទាំងនោះ
ហើយចៀមទាំងនោះមកតាមខ្ញុំ” (យ៉ូហាន ១០:២៧)។

សិទ្ធិរបស់ព្រះយេស៊ូមែននោះ មិនមែនយើងអនុវត្តតាមគំរូ
នៃជីវិតបែបនិកាយជាក់លាក់ណាមួយ ឬការថ្វាយបង្គំនោះ ទេ
ប៉ុន្តែជាការស្តាប់ព្រះសូរសៀងរបស់ព្រះអង្គ ហើយ
យើងធ្វើតាមបង្គាប់ព្រះអង្គ ដែលកើតចេញពីការស្តាប់ព្រះសូរសៀងរបស់ទ្រង់។ ច្រកផ្លូវដ៏ងាយស្រួល នាំយើងចូល
ទៅកាន់ព្រះពររបស់ព្រះជាម្ចាស់នោះគឺ ការស្តាប់ និងធ្វើ
តាមបង្គាប់ព្រះសូរសៀងរបស់ព្រះអង្គ។ លទ្ធផលចុង
ក្រោយកើតចេញពីការមិនស្តាប់ និងមិនធ្វើតាមបង្គាប់ព្រះសូរសៀងរបស់ព្រះជាម្ចាស់ គឺការទទួលបណ្តាសាមិនអាចចៀសផុតបានឡើយ។

ឥឡូវនេះ ខ្ញុំសង្ខេបឲ្យលោកអ្នកនូវបញ្ជីបណ្តាសា ខាងវិញ្ញាណ
(ខាងក្នុង) នៃចរិតលក្ខណៈរបស់យើង ដែលជា
លទ្ធផលនៃការមិនស្តាប់បង្គាប់ព្រះជាម្ចាស់។ លោកម៉ូសេ
បានរៀបរាប់អំពីបណ្តាសាទាំងនេះ
នៅក្នុងអត្ថបទព្រះគម្ពីរទុតិយកថា២៨ ។

1. នៅក្នុងខទី ២០ លោកម៉ូសេមានប្រសាសន៍ថា យើងនឹងមានភាពច្របូកច្របល់ក្នុងគ្រប់កិច្ចការទាំងអស់ ។
2. នៅក្នុងខទី២៨ យើងវង្វេងស្មារតី និងសុញគំនិត។
3. នៅក្នុងខទី៣៥ យើងខឹងសំបារចំពោះហេតុការដែល

យើងជួបប្រទៈ។

1. នៅក្នុងខទី៦៥ យើងមានចិត្តរន្ធត់ញាប់ញ័រ និងព្រួយ

បារម្ភជាខ្លាំង។

ទាំងនេះ
ជាផលវិបាកខាងព្រលឹងវិញ្ញាណខ្លះៗដែលយើងជួបប្រទៈក្នុងជីវិតប្រចាំថ្ងៃនៅពេលបច្ចុប្បន្ននេះ ដូចជាការច្របូកច្របល់ ការថប់បារម្ភ
ការឈឺចាប់ខាងក្នុង និងការរងទារុណកម្មផ្លូវចិត្ត។

តើការស្តាប់បង្គាប់ព្រះជាម្ចាស់
នាំឲ្យយើងទទួលបាននូវព្រះពរខាងវិញ្ញាណអ្វីខ្លះ? ច្រាកដណាស់
ព្រះពរទាំងនេះមានច្រើនរាប់មិនអស់ ប៉ុន្តែខ្ញុំជឿថា
ខ្ញុំអាចសង្ខេបព្រះពរទាំងនេះ
ដោយពាក្យមួយឃ្លាដែលមានអត្ថន័យខ្លាំងណាស់គឺ សេចក្តីសុខសាន្ត
(សន្តិភាព) ។

ពេលព្យាការីអេសាយបានកត់ត្រាទុកអំពីការផ្លាស់ប្តូរ
ដែលកើតមានឡើងពេលព្រះយេស៊ូសុគតនៅលើឈើឆ្កាង

ដោយសរសេរថា «លោកបានរងទារុណកម្ម
ដើម្បីអោយយើងទទួលសេចក្តីសុខសាន្ត»(អេសាយ៥៣:៥)។
ព្រះយេស៊ូទទួលការជំនុំជម្រះ និង ទទួល
ទោសជំនួសយើងដោយសារតែការមិនស្តាប់បង្គាប់
និងអំពើបាបរបស់យើង
ដើម្បីឲ្យយើងបានជានាជាមួយនឹងព្រះជាម្ចាស់ឡើងវិញ។
កាលណាយើងបានជានាជាមួយនឹងព្រះជាម្ចាស់វិញហើយ
នោះយើងអាចទទួលការផ្សះផ្សាចេញមកពីខាងក្នុង
ដែលនាំឲ្យយើងលែងច្របូកច្របល់ ថប់បារម្ភ ឈឺចាប់ខាងក្នុង
និងទារុណកម្មផ្លូវចិត្តទៀតហើយ។

យើងអាចទទួលបាន សន្តិភាពពីក្នុងជម្រៅចិត្តដ៏ពិតប្រាកដ។
សូមមើលអត្ថបទគម្ពីរពីរផ្សេងទៀត
នៅក្នុងសញ្ញាថ្មីដែលចែងអំពីសន្តិភាព។

> ដូច្នេះ ដោយព្រះជាម្ចាស់ ប្រោសយើងអោយបានសុចរិត
> ព្រោះតែយើងមានជំនឿ
> យើងក៏មានសន្តិភាពជាមួយនឹងព្រះអង្គ
> តាមរយៈព្រះយេស៊ូគ្រិស្ត ជាអម្ចាស់នៃយើងដែរ (រ៉ូម៥:១)។

> ធ្វើដូច្នេះ
> សេចក្តីសុខសាន្តរបស់ព្រះជាម្ចាស់ដែលហួសពីការស្មានរប
> ស់មនុស្ស នឹងស្ថិតជាប់ក្នុងចិត្តគំនិតបងប្អូន
> ដែលរួមក្នុងអង្គព្រះគ្រិស្តយេស៊ូមិនខាន (ភីលីព៤:៧)។

អត្ថបទគម្ពីរទាំងពីរនេះមានន័យណាស់!
យើងលែងជាប់ពិរុទ្ធទៀតហើយ
យើងលែងភ័យខ្លាចពីរបៀបធ្វើឲ្យព្រះជាម្ចាស់គាប់ព្រះហឫទ័យនឹង
យើងទៀតហើយ។
យើងមានសន្តិភាពជាមួយនឹងព្រះជាម្ចាស់ហើយ។
អត្ថបទគម្ពីរភីលីពជំពូក៤ នេះពិពណ៌នាពីលទ្ធផល
កើតចេញពីបទពិសោធន៍ ក្នៃសេចក្តីសុខសាន្តពីក្នុងជម្រៅចិត្តយើង។
សេចក្តីសុខសាន្តរបស់ព្រះជាម្ចាស់នឹងការពារចិត្ត និង គំនិតនៅក្នុង
អរិយធម៌សហសម័យនេះ។

តាមពិតពាក្យថា«សន្តិភាព»នៅក្នុងភាសាហេប្រឺមិនត្រឹមតែមានន័យ
ថា អវត្តមានជម្លោះនោះទេ តែក៏មានន័យថា ភាពពេញលេញ
ឬសុខុមាលភាពផងដែរ។

ផលប្រយោជន៍ខាងរូបកាយ

ឥឡូវនេះ សូមត្រឡប់ទៅអត្ថបទគម្ពីរទុតិយកថា ជំពូក២៨ វិញ
ដើម្បីពិនិត្យមើលពីបណ្តាសាខាងរូបកាយទាំងអស់ដែលជាលទ្ធផល
នៃការមិនស្តាប់ និងមិនធ្វើតាមបង្គាប់ព្រះសូរសៀងរបស់ព្រះអម្ចាស់។
បណ្តាសាទាំងនេះប្រាកដជាមានច្រើន នៅពេលលោកអ្នកអាន
ចូរចងចាំថាជម្ងឺទាំងអស់ខាងក្រោមនេះ
មិនមែនជាបណ្តាសាសម្រាប់ប្រជារាស្ត្ររបស់ព្រះជាម្ចាស់
ដែលបានទទួលការប្រោសលោះហើយនោះទេ។

អាសន្នរោគកើតមានចំពោះអ្នក (ខ២១) ជំងឺរាតត្បាត ជំងឺគ្រុនក្តៅ
គ្រុនរលាកគ្រុនសន្តំ (ខ២២) ឬសដូងបាត កើតបូស កើតរមាស់
(ខ២៧) ខ្វាក់ (ខ២៨) កើតដំបៅរីកពីក្បាលរហូតដល់ចុងជើង
(ខ៣៥)។

យើងមួយចំនួនជាគ្រិស្តបរិស័ទជាច្រើនកំពុងទទួលបណ្តាសា
ក្នុងពេលដែលគួររីករាយជាមួយនឹងព្រះពររបស់ព្រះជាម្ចាស់។
ហេតុអ្វី?
ប្រហែលជាមានមូលហេតុធំៗពីរៈប្រហែលមកពីយើងមិនដឹងថាវាជា
បណ្តាសា ឬក៏មកពីយើងមិនដឹងថា
ព្រះយេស៊ូបានរំដោះយើងឲ្យរួចចេញពីបណ្តាសារួចហើយ
ដើម្បីឲ្យយើងទទួលព្រះពរទុកជាមរតក។

> សូម អានទុតិយកថា ២៨:៥៩ ហើយពិចារណាមើលថាតើ
> អ្នកកំពុងរស់នៅជាប់បណ្តាសា ឬក៏ទទួលព្រះពរ។
> ព្រះអម្ចាស់នឹងប្រហារអ្នក ព្រមទាំងពូជពង្សរបស់អ្នក
> ដោយសំដែងការអស្ចារ្យ ធ្វើអោយកើតដំបៅ និងជំងឺដ៏ធ្ងន់ៗ
> ដែលពុំអាចមើលជា»។

រូបភាពរស់រវើក

ព្យាការីអេសាយ ផ្តល់ឲ្យយើងនូវរូបភាពដ៏រស់រវើក
មួយជាលទ្ធផលនៃការមិនស្តាប់បង្គាប់ និង ការបះបោរ ។
លោកមានប្រសាសន៍ពីជនជាតិអ៊ីស្រាអែល ដោយ ទំព័រ-9
លោកបានប្រៀបធៀបស្ថានភាពពួកគេ ដែលជាលទ្ធផលនៃ
ការមិនស្តាប់បង្គាប់ ទៅនឹងរូបរាងកាយទាំងមូលមានជំងឺ។

> ៥ យើងមិនដឹងថា ត្រូវវាយប្រដៅអ្នករាល់គ្នា
> ត្រង់កន្លែងណាទៀតទេ ព្រោះអ្នករាល់គ្នានៅតែបះបោរ
> ប្រឆាំងនឹងយើងជានិច្ច។
> ក្បាលរបស់អ្នករាល់គ្នារបួសសព្វទីកន្លែង
> ចិត្តរបស់អ្នករាល់គ្នាក៏មានជំងឺដែរ។ ៦
> តាំងពីក្បាលរហូតដល់ចុងជើង គ្មានអ្វីនៅល្អសោះ
> គឺមានសុទ្ធតែដំបៅ ស្នាមជាំ និងមុខរបួសថ្មីៗ
> នៅគ្រប់កន្លែង ដែលគ្មាននរណាលាង រុំ ឬលាបប្រេង
> អោយធូរស្បើយឡើយ (អេសាយ១:៥-៦)។

បទគម្ពីរនេះ
ជារូបភាពប្រៀបធៀបមួយពីលទ្ធផលនៃការមិនស្តាប់បង្គាប់។
ទោះបីជាយ៉ាងហ្នឹងក៏ដោយ
ក៏មានថ្ងៃមួយពេលខ្ញុំកំពុងអានបទគម្ពីរទាំងនេះ
ព្រះវិញ្ញាណបរិសុទ្ធបានបើកសម្តែង
ឲ្យខ្ញុំបានទទួលភាពស្រស់ស្រាយនិង អស្ចារ្យក្នុងចិត្ត។ ខ្ញុំបានដឹងថា
ព្រះយេស៊ូបានទទួលយកបណ្តាសាយើងទាំងអស់ដាក់មកលើព្រះអង្គ
ពីព្រោះទ្រង់បានទទួលបណ្តាសាជំនួសយើង។
អត្ថបទគម្ពីរទាំងនោះមិនគ្រាន់តែជារូបភាពប្រៀបធៀប
ពីស្ថានភាពប្រជាជនអ៊ីស្រាអែលដែលទទួលលទ្ធផលនៃការមិនស្តាប់
បង្គាប់ របស់ពួកគេប៉ុណ្ណោះទេ ថែមទាំងជារូបភាពរបស់ព្រះយេស៊ូ
ដែលជាប់
ពួកទាហានវ៉ូម៉ាំងវាយព្រះយេស៊ូនឹងខ្សែតីមានដៀងចំនួនប្រាំបួន
គួរឲ្យព្រឺខ្លាច។

ព្រះអង្គរងរបួលនៅត្រង់ព្រះសិរសា
ពួកគេយកភួងបន្លាមកបំពាក់លើព្រះសិរសាព្រះអង្គព្រះទ័យព្រះអង្គរ

ងការខ្វេចខ្វាំ។ ខ្ញុំជឿថា
ព្រះយេស៊ូបានសុគតដោយចិត្តសោកសង្រេង។
អត្ថបទគម្ពីរនេះពិពណ៌នាដោយត្រង់ចំពោះព្រះយេស៊ូ
ពេលទ្រង់ជាប់ឆ្កាង។ ហេតុអ្វីបានជាទ្រង់ធ្វើដូច្នេះ?
គឺដើម្បីប្រោសលោះយើងពីបណ្តាសាដោយទ្រង់ទទួលបណ្តាសាជំនួសយើង។ បណ្តាសាខាងរូបកាយទាំងអស់នោះ
គឺជាលទ្ធផលមកពីការមិនស្តាប់បង្គាប់របស់យើងដែលប្រឆាំងនឹងព្រះជាម្ចាស់ បានធ្លាក់មកលើព្រះយេស៊ូ ដែលត្រូវគេព្យួរនៅលើឈើឆ្កាង។

ឥឡូវនេះ សូមមើលព្រះពរខាងរូបកាយ
ដែលព្រះយេស៊ូបានបង់ថ្លៃជំនួសយើង។
យើងនឹងពិនិត្យមើលម្តងទៀតនៅក្នុងអត្ថបទគម្ពីរ អេសាយ ៥៣ ៤-៥ ៖

> ៤, តាមពិតលោក (ព្រះយេស៊ូ)
> បានរងទុក្ខវេទនាជំនួសយើង
> លោកទទួលយកការឈឺចាប់របស់យើងមកដាក់លើខ្លួនលោក។ រីឯយើងវិញ យើងស្មានថា
> ព្រះជាម្ចាស់បានដាក់ទោសលោក ព្រះអង្គបានវាយ
> និងបន្ទាបបន្ថោកលោក៥, ប៉ុន្តែ លោកត្រូវគេចាក់ទម្លុះ
> ព្រោះតែការបះបោររបស់យើង លោកត្រូវគេជាន់ឈ្លី
> ព្រោះតែអំពើទុច្ចរិតរបស់យើងលោកបានរងទារុណកម្ម
> ដើម្បីអោយយើងទទួលសេចក្តី សុខសាន្ត
> ហើយដោយសារស្នាមរបួសរបស់លោក
> យើងក៏បានជាសះស្បើយ។

ព្រះយេស៊ូបានទទួលយកផលវិបាកខាងរូបកាយ
ដែលកើតចេញពីការមិនស្តាប់បង្គាប់របស់យើង
ដើម្បីឲ្យយើងអាចទទួលការប្រោសឲ្យជាសះស្បើយវិញ។
យើងឃើញឃ្លានេះនៅចុងខទី៥
"ដោយសារស្នាមរបួសរបស់លោកយើងក៏បានជាសះស្បើយ"។
បើតាមភាសាហេប្រើវិញបញ្ជាក់ច្បាស់ជាងនេះ
«ស្នាមរបួសរបស់លោកធ្វើឲ្យយើងបានជាសះស្បើយ»
ឬក៏អាចនិយាយមួយបែបទៀតថា «ដោយសារស្នាមរបួសរបស់លោក
យើងបានទទួលការប្រោសឲ្យជាសះស្បើយ»។
ការប្រោសឲ្យជាសះស្បើយជាមរតករបស់យើង
តាមរយៈស្នាមរបួសនៅលើព្រះកាយព្រះយេស៊ូ។

ដំណឹងល្អម៉ាថាយ យេស៊ូ ដូចជាការប្រោសអ្នកជំងឺ
និងបណ្តេញវិញ្ញាណ អាក្រក់ជាដើម។ អត្ថបទគម្ពីរនេះចែងថា៖

> លុះដល់ល្ងាច គេនាំមនុស្សអារក្សចូលជាច្រើននាក់មករកព្រះអង្គ ព្រះអង្គក៏ដេញវិញ្ញាណទាំងនោះដោយមាន ព្រះបន្ទូល ហើយប្រោសអ្នកជំងឺអោយបានជាគ្រប់ៗគ្នា
> ស្របនឹង សេចក្តី ដែលមានចែងទុកតាមរយៈព្យាការីអេសាយថា៖ «ព្រះអង្គបានទទួលយកភាពពិការរបស់យើង
> ហើយព្រះអង្គក៏ទទួលយកជំងឺរបស់យើងដែរ»
> (ម៉ាថាយ៨១៦-១៧)។

លោកម៉ាថាយ
ពុំមានមន្ទិលសង្ស័យចំពោះការយោងអត្ថបទគម្ពីរអេសាយជំពូក ៥៣នោះឡើយ។ គឺលោកសំដៅទៅលើព្រះយេស៊ូតែម្តង។
សូមកត់សម្គាល់ផងដែរថាលោកម៉ាថាយ (គឺជាជនជាតិយូដា
ហើយយល់ភាសាហេប្រឺច្បាស់)ពុំមានមន្ទិលសង្ស័យចំពោះអត្ថបទគម្ពីរអេសាយ៥៣ ដែលសំដៅទៅលើរូបកាយ។
វាគឺជាការប្រោសអ្នកជំងឺឲ្យជាខាងរូបកាយ
ដើម្បីឲ្យសម្រេចតាមទំនាយរបស់ព្យាការីអេសាយ

សូមកត់សម្គាល់នូវព្រះបន្ទូលរបស់ព្រះយេស៊ូ ដែលបាន
ឆ្លើយតបចំពោះការរិះគន់
ដោយសារទ្រង់បានប្រោសបុរសម្នាក់ឲ្យបានជានៅថ្ងៃសប្ប៊ីទ៖

> បើអ្នករាល់គ្នាធ្វើពិធីកាត់ស្បែកនៅថ្ងៃសប្ប៊ីទតែឥតបំពានលើវិន័យរបស់លោកម៉ូសេទេ
> នោះចុះហេតុដូចម្តេចបានជាអ្នករាល់គ្នាខឹងខ្ញុំ
> ដែលបានប្រោសមនុស្សមួយទាំងមូលអោយបានជា
> នៅថ្ងៃសប្ប៊ីទដូច្នេះ? (យ៉ូហាន៧:២៣) ។

ព្រះយេស៊ូបានប្រោសមនុស្សឲ្យបានជា ទាំងស្រុង។
គ្រប់ផ្នែកទាំងអស់នៃរូបកាយ រួមទាំងបុគ្គលិកលក្ខណៈរបស់មនុស្ស
បានទទួលការប្រោសឲ្យជាតាមរយៈ ព្រះយេស៊ូ។

សូមកត់សម្គាល់ផងដែរ នូវប្រសាសន៍លោកពេត្រុស
បន្ទាប់ពីបុរសពិការជើងពីកំណើតម្នាក់ បានទទួលការ
ប្រោសឲ្យបានជានៅទ្វារលំអក្នុងអត្ថបទគម្ពីរ កិច្ចការ
៣:១៦លោកបានពន្យល់អំពីការប្រោសឲ្យជាយ៉ាងដូច្នេះថា៖

> ដោយសារយើងខ្ញុំជឿលើព្រះនាមព្រះយេស៊ូ
> គឺព្រះនាមរបស់ព្រះអង្គឬទ្ធឹងហើយបានធ្វើអោយបុរសដែលបងប្អូនឃើញ ហើយស្គាល់នេះមានកម្លាំងឡើងវិញ។

គាត់បានជាទាំងស្រុង
ដោយសារជំនឿលើព្រះយេស៊ូដូចបងប្អូនឃើញស្រាប់។
តើអ្វីទៅជាលទ្ធផល?
«ការប្រោសឲ្យជាទាំងស្រុង»ព្រះយេស៊ូមានព្រះបន្ទូលថា
«ខ្ញុំបានប្រោសមនុស្សឲ្យបានជាទាំងស្រុង»។
នេះគឺជាការប្រោសឲ្យជាជាក់ស្តែងខាងរូបកាយ
តាមរយៈការបោសលោះរបស់ព្រះយេស៊ូ។
យើងដឹងគុណចំពោះគ្រូពេទ្យ គ្រូពេទ្យចិត្តសាស្ត្រ និងអ្នកផ្សេងៗទៀត
ដែលបានព្យាបាលជំងឺយើង។ ប៉ុន្តែនៅលើសកលលោកនេះ
មានតែបុគ្គលម្នាក់ប៉ុណ្ណោះ ដែលមានប្រសាសន៍ថា៖
«ខ្ញុំប្រោសមនុស្សឲ្យបានជាទាំងស្រុង
ខ្ញុំអាចដោះស្រាយបញ្ហាទាំងអស់បាន ដូចជា
ខាងវិញ្ញាណខាងសតិបញ្ញាស្មារតី ខាងអារម្មណ៍ និងខាងរូបកាយ» ។
តើបុគ្គលនោះជានរណា? គឺ ព្រះអម្ចាស់ព្រះយេស៊ូគ្រិស្ត។

កាលណាយើងចូលមករកព្រះយេស៊ូ
ដោយពឹងផ្អែកលើជំនឿដែលជាមូលដ្ឋាននៃការប្រោសលោះនោះ
លទ្ធផលដែលកើតមានឡើង
និងបានកត់ត្រាទុកនៅក្នុងព្រះគម្ពីរសញ្ញាថ្មី
ក៏អាចកើតឡើងចំពោះអ្នក ហើយនឹងខ្ញុំ តាមរយៈជំនឿលើព្រះយេស៊ូ

នាពេលបច្ចុប្បន្ននេះដែរ។

ផលប្រយោជន៍ខាងសម្ភារៈ

ឥឡូវនេះ យើងនឹងពិនិត្យមើលព្រះពរ
និងបណ្តាសាជាពិសេសនៅក្នុងអាណាចក្រសម្ភារៈ។ ដំបូងបង្អស់
យើងពិនិត្យមើលព្រះបន្ទូលសន្យាខាងផ្នែកសម្ភារៈ
តាមការស្តាប់បង្គាប់ ពិតជាមានច្រើនណាស់។
(ខ្ញុំពុំអាចសង្ខេបនៅក្នុងបញ្ជីនេះអស់ទេ)។
លោកម៉ូសេបានកត់ត្រាទុកនៅក្នុងអត្ថបទគម្ពីរ ទុតិយកថា ២៨ថា៖

1. • ព្រះអង្គប្រទានពរអ្នកនៅតាមទីក្រុង និងនៅតាមស្រែចម្ការ

(ខ៣)។

1. ព្រះអង្គប្រទានពរឲ្យអ្នកមានកូនចៅច្រើន ឲ្យដីរបស់អ្នក

កើនភោគផលបរិបូណ៌ ហើយហ្វូងសត្វរបស់អ្នក គឺគោនិង
ចៀមក៏នឹងកើនចំនួនឡើងជាច្រើនដែរ (ខ៤)។

1. ព្រះអង្គប្រទានពរឲ្យអ្នកមានផ្លែឈើពេញល្អ ព្រមទាំង

មានស្រូវពេញជង្រុក (ខ៥)។

1. ព្រះអម្ចាស់ប្រទានពរឲ្យអ្នកមានស្រូវពេញជង្រុក ហើយ

អ្វីៗដែលអ្នកធ្វើ ព្រះអង្គប្រទានពរជានិច្ច (ខ៨)។

1. ព្រះអម្ចាស់ ជាព្រះរបស់អ្នកនឹងប្រទានឲ្យអ្នកបានចម្រុង
   ចម្រើន ដោយធ្វើអោយពូជពង្សរបស់អ្នក និងហ្វូងសត្វ

របស់អ្នកកើនចំនួនច្រើនឡើង
ហើយក៏ធ្វើឲ្យអ្នកទទួលភោគផលជាច្រើននៅលើទឹកដី
ដែលព្រះអង្គបានសន្យា

ដល់បុព្វបុរសថាប្រទានឲ្យអ្នកដែរ(ខ១១)។

ឃ្លាថា«ព្រះអម្ចាស់ ជាព្រះរបស់អ្នកនឹងប្រទានឲ្យអ្នកបាន
ចម្រុងចម្រើន» ពិពណ៌នាអំពីព្រះពរមួយ
ដែលជាលទ្ធផលបានមកពីការស្តាប់និងធ្វើតាមបង្គាប់ព្រះសូរសៀង
របស់ព្រះអម្ចាស់។ លោកម៉ូសេសង្ខេបផ្នែករឿងដូចគ្នាទៅនឹង ទុតិយកថា
២៩ដូច្នេះអ្នករាល់គ្នាត្រូវកាន់
និងប្រតិបត្តិតាមសេចក្តីដែលមានចែងទុកក្នុងសម្ពន្ធមេត្រីនេះ

> ដើម្បីអោយអ្នករាល់គ្នាទទួលជោគជ័យ (ចម្រុងចម្រើន)
> ក្នុងគ្រប់កិច្ចការដែលអ្នករាល់គ្នាធ្វើ។

ការប្រតិបត្តិតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់
ដែលមានចែងនៅក្នុងសម្ពន្ធមេត្រី
នឹងនាំឲ្យយើងទទួលភាពចម្រុងចម្រើន គ្រប់វិស័យទាំងអស់។
វាគ្មានចន្លោះទុកសម្រាប់ការបរាជ័យ
ឬការខកចិត្តនៅផ្នែកណាមួយនៃជីវិតរបស់យើងបានឡើយ។

ព្រះពរទាំងនេះគឺជាព្រះបន្ទូល

សន្យាដោយការស្តាប់បង្គាប់។
ឥឡូវនេះសូមពិនិត្យមើលបណ្តាសាខាងសម្ភារៈចំពោះការមិនស្តាប់ប
ង្គាប់វិញម្តង។សូមយើងអាន ទុតិយកថា ២៨:២៩៖

> អ្នកនឹងដើររាវរៅពេលថ្ងៃត្រង់ ដូចមនុស្សខ្វាក់ដើរស្ទាបៗ
> ក្នុងភាពអន្ធការ អ្នកពុំអាចសំរេចតាម
> គំរោងការដែលអ្នករៀបចំឡើយ។

ភាពចម្រុងចម្រើនគឺជាព្រះពរ ដូច្នេះការវិនាស
អន្តរាយគឺជាបណ្តាសា។ដើម្បីឲ្យកាន់តែច្បាស់ជាងនេះ ទៀត
លោកប៉ូលបានថ្លែងនៅក្នុងអត្ថបទគម្ពីរទុតិយកថា២៨:៤៧-៤៨។
គឺថាព្រះពរ ហើយនឹងបណ្តាសានៅជ្រុង ម្នាក់ម្ខាង

> «នៅពេលសម្បូណ៌សប្បាយ ប្រសិនបើអ្នកពុំគោរព
> បំរើព្រះអម្ចាស់ ជាព្រះរបស់អ្នក
> ដោយអំណរនិងដោយស្មោះអស់ពីចិត្តទេ
> នោះអ្នកនឹងបំរើខ្មាំងសត្រូវដែលព្រះអម្ចាស់ចាត់អោយមក
> ប្រហារអ្នក។ អ្នកនឹងស្រេកឃ្លាន ខ្លួនទទេ
> ហើយខ្វះខាតអ្វីៗទាំងអស់។លោកអ្នកមិនអាចរកឃើញរូប
> ភាពណា
> ច្បាស់ជាងរូបភាពនៃខគម្ពីរទាំងពីរខាងលើនេះទៀតទេ។

លទ្ធផល កើតចេញពីការស្តាប់បង្គាប់គឺ
ភាពសម្បូណ៌សប្បាយគ្រប់វិស័យទាំងអស់
ការគោរពបម្រើព្រះអម្ចាស់ដោយអំណរ និងស្មោះអស់ពីចិត្ត។
លទ្ធផលកើតចេញពីការមិនស្តាប់បង្គាប់វិញគឺ បម្រើខ្មាំងសត្រូវ
ស្រេកឃ្លាន ខ្លួននៅអាក្រាត ហើយភាពខ្វះខាតគ្រប់សព្វ។

ថ្ងៃមួយ ពេលខ្ញុំកំពុងតែសញ្ជឹងគិតពីព្រះបន្ទូលទាំង នេះ
ខ្ញុំឃើញឃ្លាមួយពិពណ៌នាភាពក្រីក្រគោកយ៉ាក។មនុស្សម្នាក់ឃ្លាន
តែពុំមានអ្វីបរិភោគ ស្រេកពុំមានអ្វីផឹក
ខ្លួននៅអាក្រាតពុំមានខោអាវស្លៀកពាក់ ហើយខ្វះខាតសព្វគ្រប់។
មនុស្សនោះពិតជាស្ថិតនៅក្នុងស្ថានភាពក្រីក្រមែន។
ពុំមានរូបភាពណាផ្សេងទៀត
ដែលបង្ហាញពីភាពក្រីក្រច្បាស់ជាងនេះទៀតនោះទេ៖ ការឃ្លាន
ការស្រេក ខ្លួននៅទទេ និងខ្វះខាតសព្វគ្រប់។
សេចក្តីពិតប្រាប់យើងថា ភាពក្រីក្រនោះគឺជាបណ្តាសា
ហើយបណ្តាសានេះមិនមែនសម្រាប់ប្រជារាស្ត្ររបស់ព្រះជាម្ចាស់នោះ
ទេ។ តើជាអំណរដល់ព្រលឹងខ្ញុំអ្វីម្ល៉េះទេ? ដែលបានដឹងច្បាស់ថា
ភាពក្រីក្រគឺមិនមែនសម្រាប់កូនរបស់ព្រះជាម្ចាស់ទេ
ហើយក៏មិនមែនសម្រាប់ប្រជារាស្ត្ររបស់ព្រះជាម្ចាស់
ដែលព្រះជាម្ចាស់បានប្រោសលោះរួចហើយនោះដែរ។ តែផ្ទុយទៅវិញ
ព្រះជាម្ចាស់មានព្រះហឫទ័យចង់ឲ្យបានសម្បូណ៌សប្បាយ
ដើម្បីឲ្យយើងបម្រើព្រះអង្គដោយអំណរ និងចិត្តរីករាយ។

មានពេលមួយ
កាលខ្ញុំកំពុងអធិប្បាយនៅក្រុមជំនុំមួយក្នុងប្រទេសនូវែលសេឡង់
ស្រាប់តែព្រះវិញ្ញាណបរិសុទ្ធបានបង្ហាញខ្ញុំពីអ្វីមួយ
ដែលស្ថិតនៅជាប់ក្នុងគំនិត និងវិញ្ញាណខ្ញុំជារៀងរហូត។
ព្រះវិញ្ញាណបរិសុទ្ធបានបង្ហាញខ្ញុំពីព្រះយេស៊ូជាប់ឈើឆ្កាង។
ព្រះអង្គឃ្លាន ស្រេកទឹក ខ្លួននៅអាក្រាត និងខ្វះខាតសព្វគ្រប់។
ហេតុអ្វីបានជាដូច្នេះ? ពិត ប្រាកដមែន ព្រះអង្គបានខ្សោះអស់កម្លាំង
ដោយសារតែបណ្តាសានៃភាពក្រីក្រជំនួសយើង។
ព្រះអង្គបានដកបណ្តាសារបស់យើងទាំងអស់ម្តងជាសំរេច។ ហេតុអ្វី?
ព្រោះអ្នកហើយនឹងខ្ញុំជាអ្នកជឿ
ដែលបានទទួលការប្រោសលោះតាមរយៈព្រះលោហិតរបស់ព្រះយេ
ស៊ូ ហើយមិនត្រូវរងទុក្ខដោយនឹមដែក
ដែលជាបណ្តាសានៃភាពក្រីក្រទៀតទេ។

ការដោះដូររបស់ព្រះជាម្ចាស់

ភាពក្រីក្រមិនមែនជាព្រះពរ ដែលកើតចេញពីការស្តាប់បង្គាប់នោះទេ
ប៉ុន្តែកើតមកពីការមិនស្តាប់បង្គាប់។សូមអរព្រះគុណព្រះជាម្ចាស់
ទោះបីជាយើងទាំងអស់គ្នាមិនបានស្តាប់បង្គាប់ក៏ដោយ
ក៏ព្រះយេស៊ូបានទទួលយកទុច្ចរិតភាពរបស់យើងទាំងអស់មកដាក់
លើអង្គទ្រង់។ ការបះបោររបស់យើង និងផលវិបាកដ៏អាក្រក់ទាំងអស់
រួមទាំងភាពក្រីក្រផងដែរ ត្រូវបានយកមកដាក់លើអង្គព្រះយេស៊ូ
នៅពេលគេឆ្កាងព្រះអង្គលើឈើឆ្កាង។

ការដោះដូរនេះ ត្រូវបានសង្ខេបយ៉ាងច្បាស់នៅក្នុងព្រះគម្ពីរសញ្ញាថ្មី
២កូរិនថូស
ដោយបង្ហាញទិដ្ឋភាពពីរចេញពីការដោះដូរនៅក្នុងអាណាចក្រខាងស
ម្ភារៈ។ លោកប៉ូលមានប្រសាសន៍ថា៖

> ដ្បិតបងប្អូនស្គាល់ព្រះគុណរបស់ ព្រះអម្ចាស់យេស៊ូ
> គ្រិស្តស្រាប់ហើយ គឺព្រះអង្គមានសម្បត្តិដ៏ច្រើន
> ទ្រង់បានដាក់ខ្លួនមកជាអ្នកក្រ ព្រោះតែបងប្អូន
> ដើម្បីអោយបងប្អូនបានទៅជាអ្នកមាន
> ដោយភាពក្រីក្ររបស់ព្រះអង្គ(២កូរិនថូស៨ ៩)

> ព្រះអង្គ
> ទ្រង់អាចនឹងប្រទានពរដ៏ហូរហៀរគ្រប់យ៉ាងដល់បងប្អូន
> ដើម្បីអោយបងប្អូនមានអ្វីៗទាំងអស់ដែលបងប្អូនត្រូវការដ៏
> ចាំបាច់នោះជានិច្ច
> ហើយថែមទាំងនៅសល់បរិបូណ៌សំរាប់ចែកទានផង។
> (២កូរិនថូស៩ ៨)

តើការដោះដូរនោះគឺជាអ្វី?
ព្រះយេស៊ូបានទទួលយកភាពក្រីក្ររបស់យើងដាក់នៅលើឈើឆ្កាង
ដើម្បីឲ្យយើងមានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិដ៏បរិបូណ៌ហូរហៀរ
របស់ទ្រង់តាមរយៈព្រះគុណ
ហើយព្រះគុណនោះបានមកតាមរយៈព្រះយេស៊ូតែមួយអង្គគត់។
ព្រះគុណមិនអាចរកបានទេព្រោះព្រះគុណជាអំណោយតាមរយៈជំ
នឿតែប៉ុណ្ណោះ។

នៅក្នុងភាសាក្រិក សេចក្តីដែលមានចែងនៅក្នុង២កូរិនថូស៩៨
អស្ចារ្យណាស់។ ពាក្យថាមាន បរិបូណ៌ មានពីរដង និងពាក្យថា
ទាំងអស់ មានដល់ទៅប្រាំដង!
នេះជាអំណោយរបស់ព្រះយេស៊ូប្រទានឲ្យយើង
គឺព្រះអង្គឡោះអស់កម្លាំង ដោយបណ្តាសានៃភាពក្រីក្រ
ដើម្បីឲ្យយើងទទួលព្រះពរទុកជាមរតក។

ព្រះយេស៊ូបានប្រទានព្រះពរទាំងបីផ្នែកឲ្យយើងគឺ ព្រះពរខាងវិញ្ញាណ
ព្រះពរខាងរូបកាយ
និងព្រះពរខាងសម្ភារៈដែលសង្ខេបមកនៅក្នុងសំបុត្រសាវ័ក យ៉ូហាន
៣ : ២ ថា៖

> ប្អូនជាទីស្រឡាញ់
> ខ្ញុំសូមជូនពរអោយប្អូនបានប្រកបដោយសេចក្តីសុខគ្រប់ជំ
> ពូកទាំងអស់គឺ អោយប្អូនមានសុខភាពល្អបរិបូណ៌
> ដូចព្រលឹងរបស់ប្អូនដែលបានប្រកបដោយសេចក្តីសុខហើ
> យនោះដែរ។

ព្រះជាម្ចាស់ មានព្រះទ័យឲ្យយើងទទួលព្រះពរទុកជាមរតក
ក្នុងនាមអ្នកជឿលើព្រះយេស៊ូគ្រិស្ត។

: TL-L097-100-KHM
: 18 Nov 2025
: derekprince.com/km/resources


«ព្រះវិញ្ញាណបរិសុទ្ធជ្រាបផ្លូវ
ពី
ព្រះទ្រង់ជាអ្នកដែលបានគូសផែនទី។»
derekprince.com/km/resources
Cut here to use as a bookmark